**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសុខាភិបាល
លេខ.៣៦៣.សរ១៩

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធាន**
**គណៈកម្មការអន្តរក្រសួង ដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩**
**ជម្រាបជូន**
**ឯកឧត្តម លោកជំទាវ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួង ស្ថាប័នពាក់ព័ន្ធ**
**ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី-ខេត្តទាំង ២៥**

**កម្មវត្ថុ ៖** អនុវត្តយុទ្ធនាការ អប់រំ ផ្សព្វផ្សាយ និងបណ្តុះបណ្តាលប្រជាពលរដ្ឋ ក្រោមប្រធានបទ ***"រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩"*** ដើម្បីជំរុញការទទួលខុសត្រូវរបស់បុគ្គល គ្រួសារ សហគមន៍ ស្ថាប័នពាក់ព័ន្ធជាពិសេសសេវាឯកជន អាជ្ញាធរមូលដ្ឋាន រួមគ្នាទទួលខុសត្រូវក្នុងស្មារតីសាមគ្គីភាព ដើម្បីកាត់ផ្តាច់ខ្សែចម្លងវីរុសកូវីដ-១៩ ព្រមទាំង រស់នៅជាមួយនឹងវីរុសកូវីដ-១៩ តាមគន្លងប្រកតីភាពថ្មីឲ្យបានត្រឹមត្រូវ។

**យោង ៖** សេចក្តីណែនាំអំពីការងារមួយចំនួនពាក់ព័ន្ធនឹងការអនុវត្តផែនការយុទ្ធសាស្ត្រចាក់វ៉ាក់សាំងកូវីដ-១៩ និងការរៀបចំ"យុទ្ធនាការអនុវត្តយុទ្ធសាស្ត្រ ៦ ចំណុចរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** សំដៅទប់ស្កាត់លេកទី៣ នៃការឆ្លងរាលដាលជំងឺកូវីដ-១៩ និងដើម្បីត្រៀមខ្លួនរស់ជាមួយជំងឺកូវីដ-១៩ ក្នុងគន្លងប្រក្រតីភាពថ្មី"របស់ **គណៈប្រចាំការនៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ (គបក)**។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន ឯកឧត្តម លោកជំទាវ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួង ស្ថាប័នពាក់ព័ន្ធ ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី-ខេត្តទាំងអស់ជ្រាបថា យុទ្ធនាការអនុវត្តយុទ្ធសាស្ត្រ ៦ ចំណុចរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** សំដៅទប់ស្កាត់លេកទី៣ នៃការឆ្លងរាលដាលជំងឺកូវីដ-១៩ និងដើម្បីត្រៀមខ្លួនរស់ជាមួយជំងឺកូវីដ-១៩ ក្នុងគន្លងប្រក្រតីភាពថ្មីកំពុងតែដំណើរការយ៉ាងសកម្ម ដើម្បីទប់ស្កាត់ស្ថានភាពពគស្បាតនៃជំងឺកូវីដ-១៩។ ទន្ទឹមនឹងនេះដើម្បីទាក់ទាញប្រជាពលរដ្ឋឲ្យបង្កើនការយកចិត្តទុកដាក់ខ្ពស់ឡើងវិញក្នុការប្រកាន់ខ្ជាប់នូវវិធានការសុវត្ថិភាពផ្នែកសុខាភិបាល ជាពិសេសវិធានការ " **៣ការពារ និង៣កុំ**" ព្រមទាំងផ្លាស់ប្តូរឥរិយាបថ ដើម្បីរៀនរស់នៅជាបណ្តើរៗជាមួយនឹងវត្តមាននៃមេរោគកូវីដ-១៩ គណៈកម្មការអន្តរក្រសួងប្រយុទ្ធនឹងជំងឺកូវីដ-១៩ បានដាក់ចេញនូវ លិខិតចុះថ្ងៃទី២៦ ខែកក្កដាកន្លងមក ស្តីពីការអនុវត្តយុទ្ធនាការទូទាំងប្រទេស ដើម្បីអប់រំ ផ្សព្វផ្សាយ និងបណ្តុះបណ្តាលប្រជាពលរដ្ឋឲ្យយល់ដឹងអំពីគ្រោះថ្នាក់នៃវីរុសកូវីដ-១៩ ដែលត្រូវបន្តជាប់ជាប្រចាំដោយស្មារតីយកចិត្តទុកដាក់ខ្ពស់ ។



ទីស្តីការក្រសួងសុខាភិបាល ផ្ទះលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

យុទ្ធនាការអប់រំផ្សព្វផ្សាយអំពីវិធានការការពារជំងឺកូវីដ-១៩បានធ្វើឡើងយ៉ាងច្រើនក្នុងរយៈពេលកន្លងមក។ ប៉ុន្តែសកម្មភាពទាំងអស់នោះមិនទាន់គ្រប់គ្រាន់សម្រាប់ឆ្លើយតបទៅនឹងស្ថានភាពនៃការចម្លងវីរុសកូវីដ-១៩នាបច្ចុប្បន្ន។ ដូច្នេះការរៀបចំបន្តយុទ្ធនាការដែលមានលក្ខណៈផ្តោតចំពោះ និងមានកិច្ចសហការរវាងភាគីពាក់ព័ន្ធទាំងអស់ ដោយល្អិតល្អន់ និងសម្រុកក្នុងពេលតែមួយចាប់ពីពេលនេះតទៅគឺមានសារៈសំខាន់បំផុត ដើម្បីឈានទៅសម្រេចបានការផ្លាស់ប្តូរឥរិយាបថរបស់ប្រជាជនក្នុងការរស់នៅតាមបែបគន្លងថ្មីជាមួយ វីរុសកូវីដ-១៩ ។ ជាមួយគ្នានេះ អនុគណៈកម្មការអប់រំ បណ្តុះបណ្តាល និងទំនាក់ទំនងសាធារណៈ នៃគណៈកម្មការអន្តរក្រសួងប្រយុទ្ធនឹងជំងឺកូវីដ-១៩ ក៏បានរៀបចំជាសេចក្តីណែនាំក្នុងការរៀបចំយុទ្ធនាការអប់រំ ផ្សព្វផ្សាយ និងបណ្តុះបណ្តាលប្រជាពលរដ្ឋ ក្រោមប្រធានបទ ***"រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩"*** (ដូចជូនភ្ជាប់មកជាមួយ) ដើម្បីជាមគ្គុទ្ទេសជំនួយបន្ថែមក្នុងការរៀបចំអនុវត្តយុទ្ធនាការថ្នាក់ជាតិនេះឲ្យកាន់តែមានប្រសិទ្ធភាព។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោកជំទាវ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត មេត្តាចូលរួមជំរុញយុទ្ធនាការពញ្ញាក់ស្មារតីសាមគ្គីភាព និងការទទួលខុសត្រូវរបស់ភាគីពាក់ព័ន្ធក្រោមសមត្ថកិច្ចរបស់ឯកឧត្តម លោកជំទាវ និងបុគ្គលគ្រប់រូប ក្នុងការចូលរួមទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ ដោយរៀបចំសកម្មភាពសំខាន់ៗតាមសេចក្តីណែនាំយុទ្ធនាការនេះដោយស្មារតីទទួលខុសត្រូវខ្ពស់។

សូមឯកឧត្តម លោកជំទាវ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ទទួលនូវការគោរព និងស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

ថ្ងៃចន្ទ ៩កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ទោស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធាន**

**គណៈកម្មការអន្តរក្រសួង ដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩**

ម៉ម ប៊ុនហេង



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩